ស្ថានទូតអូស្ត្រាលី ប្រចាំព្រះរាជាណាចក្រកម្ពុជា

Australian Aid

PONLOK CHOMNES

The Asia Foundation

វេទិកាអនាគត FUTURE FORUM

# សេចក្ដីប្រកាសព័ត៌មានរួម

ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦

## រដ្ឋាភិបាលអូស្ត្រាលី អង្គការមូលនិធិអាស៊ី និងវេទិកាអនាគត  អបអរអ្នកវិភាគគោលនយោបាយជំនាន់ក្រោយកម្ពុជា

ថ្ងៃនេះ វេទិកាអនាគត សហការជាមួយរដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី បានរៀបចំពិធីបញ្ចប់វគ្គសិក្សាស្រាវជ្រាវគោលនយោបាយបរិយាបន្ន ២០២៥ (Inclusive Policy Fellowship 2025) និងសម្ពោធសៀវភៅក្រោមចំណងជើងថា «**គំនិតតូចសម្រាប់អនាគតប្រកបដោយបរិយាបន្ន**» (**Small Ideas for Inclusive Futures**)។

ពិធីនេះប្រព្រឹត្តទៅដោយមានវត្តមានចូលរួមយ៉ាងកុះករ ពីតំណាងរាជរដ្ឋាភិបាលកម្ពុជា អ្នកដឹកនាំគ្រឹះស្ថានស្រាវជ្រាវសង្គមស៊ីវិល និងបណ្ដាអ្នកស្រាវជ្រាវជាន់ខ្ពស់មួយចំនួនទៀត ដើម្បីអបអរអ្នកស្រាវជ្រាវវ័យក្មេងឆ្នើមទាំង ២៨រូប របស់វេទិកាអនាគត ដែលបានវិវត្តខ្លួនពីសិក្ខាកាម ទៅជាអ្នកដឹកនាំផ្នែកគំនិតយោបល់។

អំឡុងពេល១២ខែកន្លងមក ក្រុមអ្នកស្រាវជ្រាវគោលនយោបាយដែលមានសាវតាចម្រុះគ្នា រួមមានស្ត្រី ជនជាតិដើមភាគតិច អ្នកស្វែងរងការគាំទ្រមតិ LGBTQ+ បានឆ្លងកាត់ការហ្វឹកហ្វឺនដ៏ម៉ត់ចត់លើជំនាញវិភាគគោលនយោបាយ ក្នុងក្របខណ្ឌនៃកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ ដែលបានទទួលការឧបត្ថម្ភគាំទ្រពីរដ្ឋាភិបាលអូស្ត្រាលី។ ស្នាដៃរបស់អ្នកស្រាវជ្រាវវ័យក្មេងទាំងនេះត្រូវបានចងក្រងជាដំណោះស្រាយគោលនយោបាយសាធារណៈសរុបចំនួន៣០ ដែលផ្ដួចផ្ដើមដោយយុវជន ផ្ដោតទៅលើអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព សមធម៌រចនាសម្ព័ន្ធសង្គម និងអន្តរាគមន៍ពោរពេញដោយប្រសិទ្ធភាពរបស់រដ្ឋ ដែលត្រូវបានចងក្រងជាសៀវភៅស្នាដៃបិទបញ្ចប់វគ្គ ដើម្បីចូលរួមលើកកម្ពស់ការពិភាក្សាសាធារណៈរបស់ពលរដ្ឋដោយមានមូលដ្ឋានលើភស្តុតាងនៅកម្ពុជា។

នៅក្នុងពិធីនេះ ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានគូសបញ្ជាក់អំពីការគាំទ្រយូរអង្វែងរបស់អូស្ត្រាលីចំពោះវិស័យស្រាវជ្រាវនៅកម្ពុជា។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានកត់សម្គាល់ពីផលវិជ្ជមានដែលបង្កើតឡើងដោយប្រជាពលរដ្ឋវ័យក្មេងកម្ពុជា និងសារៈសំខាន់នៃការវិនិយោគលើជំនាញ គំនិត និងភាពជាអ្នកដឹកនាំរបស់យុវជន។ ឯកឧត្តមបានមានប្រសាសន៍ថា វគ្គស្រាវជ្រាវគោលនយោបាយបរិយាបន្ន (Inclusive Policy Fellowship) ឆ្លុះបញ្ចាំងពីការគាំទ្រយ៉ាងទូលំទូលាយរបស់អូស្ត្រាលី ទៅលើការអភិវឌ្ឍមូលធនមនុស្ស និងអនាគតអ្នកដឹកនាំកម្ពុជា តាមរយៈការរួមចំណែករបស់អ្នកស្រាវជ្រាវគោលនយោបាយវ័យក្មេងក្នុងការបង្កើតភស្តុតាង និងទស្សនៈថ្មីៗ លើកិច្ចការនានា រួមមានរបបពន្ធដារប្រកបដោយវិវឌ្ឍនភាព លំហាវិមជ្ឈការសាធារណៈ  ប្រាក់ចំណូលមូលដ្ឋានឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធដែលឆ្លើយតបនឹងយេនឌ័រ។

អ្នកស្រី Dolgion Aldar នាយិកាកម្មវិធីពន្លកចំណេះ ដំណាក់កាលទី២ បានលើកឡើងពីភាពជាដៃគូយុទ្ធសាស្ត្ររបស់កម្មវិធីជាមួយវេទិកាអនាគត។ អ្នកស្រីបានមានប្រសាសន៍ថា៖ «យុវជនមិនតែងតែទទួលបានលំហរគ្រប់គ្រាន់ក្នុងការ

ចូលរួមពិភាក្សាគោលនយោបាយទេ ប៉ុន្តែកម្មវិធីនេះបានស្វែងឱ្យឃើញពីលទ្ធភាពដែលអាចសម្រេចបាន នៅពេលដែលពួកគេទទួលបានឱកាស។ អ្នកស្រាវជ្រាវគោលនយោបាយក្នុងវគ្គនេះ បានប្រើប្រាស់ភស្តុតាង បទពិសោធន៍ជាក់ស្តែង និងជំនាញស្រាវជ្រាវគោលនយោបាយដ៏រឹងមាំ ដើម្បីចូលរួមដោះស្រាយបញ្ហាស្មុគ្រស្មាញក្នុងសង្គម។ អ្នកស្រាវជ្រាវទាំងនេះបាននាំយកការវិភាគរបស់ពួកគេសម្រាប់ចូលរួមក្នុងវេទិកាសាធារណៈ សារព័ត៌មានជាតិនិងកិច្ចសន្ទនាដោយផ្ទាល់ជាមួយអ្នកធ្វើសេចក្តីសម្រេចផ្នែកគោលនយោបាយ ដោយបង្ហាញពីរបៀបដែលអ្នកស្រាវជ្រាវវ័យក្មេង អាចចូលរួមប្រកបដោយអត្ថន័យក្នុងការរួមចំណែកក្នុងកិច្ចសន្ទនាគោលនយោបាយនៅកម្ពុជានាពេលបច្ចុប្បន្ន»។

ពិធីនេះក៏មានការប្រគល់វិញ្ញាបនបត្រជាផ្លូវការ ការផ្សព្វផ្សាយសៀវភៅ និងបទបង្ហាញពីអ្នកស្រាវជ្រាវវ័យក្មេងតំណាងវគ្គចំនួន៣រូប ចែករំលែកអំពីបទពិសោធន៍ចូលរួមក្នុងវគ្គខាងលើ រួមទាំងការស្រាវជ្រាវរបស់ពួកគេ។ សៀវភៅស្នាដៃចុងក្រោយ «គំនិតតូចសម្រាប់អនាគតប្រកបដោយបរិយាបន្ន» បានស្វែងរកដំណោះស្រាយផ្តោតលើមនុស្ស និងបញ្ហាសំខាន់ៗ តាមរយៈមូលបទ៦ រួមមាន ការលើកកម្ពស់សិទ្ធិពលរដ្ឋដោយស្មើភាព ការកំណត់ឡើងវិញនូវកិច្ចសន្យាសង្គម ការកសាងសេដ្ឋកិច្ចប្រកបដោយយុត្តិធម៌ ការអប់រំសម្រាប់អាជីពនាពេលអនាគត កិច្ចការការពារសុខុមាលភាពប្រជាជន និងការរចនាលំហរស់នៅដោយផ្តោតលើមនុស្ស៕

*វគ្គស្រាវជ្រាវគោលនយោបាយបរិយាបន្ន (Inclusive Policy Fellowship) គឺជាគំនិតផ្តួចផ្តើមមួយក្នុងក្របខណ្ឌកម្មវិធី Ponlok Chomnes II: Data and Dialogue for Development in Cambodia ដែលទទួលថវិកាពីរដ្ឋាភិបាលអូស្ត្រាលី និងអនុវត្តដោយ អង្គការមូលនិធិអាស៊ី។ កម្មវិធីនេះមានគោលបំណងពង្រឹងវិស័យស្រាវជ្រាវនៅកម្ពុជា តាមរយៈការកសាងកិច្ចសហការរវាងអ្នករៀបចំគោលនយោបាយ អ្នកស្រាវជ្រាវ និងសហគមន៍ ព្រមទាំងបញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម ទៅក្នុងការស្រាវជ្រាវ និងកិច្ចសន្ទនាគោលនយោបាយ។*

**ទំនាក់ទំនងសារព័ត៌មាន**


- ស្ថានទូតអូស្ត្រាលី៖ Media.Cambodia@dfat.gov.au
- អង្គការមូលនិធិអាស៊ី៖ Ponlok.Chomnes@asiafoundation.org
- វេទិកាអនាគត៖ chhengpor.aun@futureforum.asia